## បូជាគ្រឿងសក្ការ

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។**

*ប្រែថា៖ ខ្ញុំព្រះករុណា សូមបូជានូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាយូរអង្វែងទៅហោង ។*

*(ក្រាបថ្វាយបង្គំម្ដង)*

## ពុទ្ធរតនប្បណាម

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

*( សូត្របីចប់)*

*ប្រែថា៖ វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណាចូរមាន ដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

*(ក្រាបថ្វាយបង្គំម្ដង)*

# ពុទ្ធានុស្សតិ

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

**ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា* **អរហំ** *ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងកាយបយោគ និងវចីបយោគ,* **សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា* **សម្មាសម្ពុទ្ធោ** *ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ,* **ភគវា** *ទ្រង់ព្រះនាមថា* **ភគវា** *ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់មកកើតទៀតឡើយ,* **វិជ្ជាចរណ-សម្បន្នោ** *ទ្រង់ព្រះនាមថា* **វិជ្ជាចរណសម្បន្នោ** *ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និង វិជ្ជា ៨ និង ចរណៈ ១៥,* **សុគតោ** *ទ្រង់ព្រះនាមថា* **សុគតោ** *ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមត-មហានិព្វាន,* **លោកវិទូ** *ទ្រង់ព្រះនាមថា* **លោកវិទូ** *ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក,* **អនុត្តរោ** *ទ្រង់ព្រះនាថា* **អនុត្តរោ** *ព្រោះព្រះអង្គ*

*ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន,* **បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថាបុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន,* **សត្ថា ទេវមនុស្សានំ** *ទ្រង់ព្រះនាមថា* **សត្ថា ទេវមនុស្សានំ** *ព្រោះព្រះអង្គជាសាស្ដាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ,* **ពុទ្ធោ** *ទ្រង់ព្រះនាមថា* **ពុទ្ធោ** *ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង,* **ភគវា** *ទ្រង់ព្រះនាមថា* **ភគវា** *ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់មកកើតទៀតឡើយ,* **តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** *ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណាមានគុណាថា* **អរហំ** *ជាដើមនោះ ដោយសិរសាគឺត្បូង* **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណោះ ។*

*(ក្រាបថ្វាយបង្គំម្ដង)*

 

# ធម្មានុស្សតិ

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំវេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ស្វាក្ខាតោ ភគវតា ធម្មោ *ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយល្អ* (ធម្មោ *ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១),* សន្ទិដ្ឋិកោ *ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណគឺថានឹងបានដោយស្ដាប់ដោយជឿបុគ្គលដទៃនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង,* អកាលិកោ *ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានឃឹតយូរឡើយ,* ឯហិបស្សិកោ *ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន,* ឱបនយិកោ *ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា,* បច្ចត្តំវេទិតព្វោ វិញ្ញូហីតិ *ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ*

មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន, **តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា ស្វាក្ខាតា ជាដើមនោះដោយសិរសាគឺត្បូង **តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

*(ក្រាបថ្វាយបង្គំម្តង)*



# សង្ឃានុស្សតិ

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃគឺប្រតិបត្តិតាមគន្លងព្រះនពលោកុត្តរធម៌,* **ឧជុបដិបន្នោ ភគវតោ សាវក សង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាជាមជ្ឈិមាបដិបទា,* **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេមផុតចាកទុក្ខទាំងពួង,* **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃ*

*ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា,* **យទិទំ ចត្តារិ បុរិសយុគានិ** *ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៨ គូ គឺព្រះសង្ឃដែលបានសម្រេចនូវ**សោតាបត្តិមគ្គ** និង**សោតាបត្តិផល**ជាគូ ១ **សកទាគាមិមគ្គ** និង**សកទាគាមិផល**ជាគូ ១ **អនាគាមិមគ្គ** និង**អនាគាមិផល**ជាគូ ១ **អរហត្តមគ្គ** និង**អរហត្តផល**ជាគូ ១,* **អដ្ឋ បុរិសបុគ្គលា** *បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវ**សោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១**,* **ឯស ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,* **អាហុនេយ្យោ** *លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា,* **បាហុនេយ្យោ** *លោកគួរទទួលនូវអាគន្តុកទានគឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្តដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា,* **ទក្ខិណេយ្យោ** *លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា,* **អញ្ជលិករណីយោ** *លោកគួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ,* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ**

*លោកជាបុញ្ញខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន* **តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** *ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ដ៏ប្រកបព្រមដោយគុណមានគុណថា* **សុបដិបន្នោ** *ជាដើមនោះដោយត្បូង* **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។*

*(ក្រាបថ្វាយបង្គំម្តង)*

